# មេរៀនទី ៣២: ព្រះបានធ្វើឱ្យទឹកជំនន់លិចផែនដី

## លោកុប្បត្តិ ៧-៨, ៩:៨-១៦

**គោលបំណង៖** យើងតែងតែអាចពឹងផ្អែកលើព្រះបានជានិច្ច។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៣៣:២០** *"ព្រលឹងនៃយើងខ្ញុំសង្ឃឹមដល់ព្រះយេហូវ៉ា ទ្រង់ជាជំនួយ ហើយជាខែល របស់យើងខ្ញុំ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកយល់យ៉ាងណាចំពោះពាក្យសន្យា? តើអ្នកអាចរក្សាការសន្យាបានទេ? តើអ្នកអាចទុកចិត្តមិត្តភក្តិដែលបានសន្យាអ្វីមួយជាមួយអ្នកដែរឬទេ? ពេលដែលព្រះធ្វើការសន្យា អ្នកអាចជឿទុកចិត្តថាគ្មានអ្វីនៅលើផែនដីអាចបញ្ឈប់ព្រះអង្គក្នុងការរក្សាសន្យារបស់ទ្រង់បានឡើយ។ ការសន្យារបស់ព្រះនាំមកនូវការកំសាន្តចិត្ត ក្តីសង្ឃឹម និងសន្តិភាព។ សូមគិតពីសេចក្តីសន្យាទាំងអស់ដែលព្រះបានរក្សានៅក្នុងព្រះគម្ពីរ។ សូមអរព្រះគុណព្រះសំរាប់ការរក្សាការសន្យារបស់ទ្រង់!

**ចំរៀង៖** ១. លោកតាណូអេ ២.ក្នុងពេលទ្រង់ ៣. ក្តីសុខសាន្ត

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ៣. ល្បែងកំសាន្ត «ចំលងមិត្តភក្តិ»



**សម្ភារៈដែលត្រូវការ៖** ខ្សែ

១. ឲ្យកុមារចាប់ដៃគូពីរៗនាក់ ហើយឈរទន្ទឹមគ្នា

២. កុមារម្នាក់ត្រូវឈរបែរមុខមកខាងមុខ ហើយកុមារម្នាក់ទៀតត្រូវឈរបែរមុខទៅក្រោយ។ គ្រូនឹងឲ្យខ្សែទៅកុមារគ្រប់ក្រុម បន្ទាប់មកពួកគេត្រូវចងជើងពួកគេម្នាក់ម្ខាង។

៣. នៅពេលដែលគ្រូនិយាយថា "១ ២ ៣ ទៅ" កុមារគ្រប់ក្រុមទាំងអស់ត្រូវដើរទៅកាន់ទី ហើយត្រឡប់មកវិញ។

៤. ក្រុមណាដែលអាចត្រឡប់កកាន់ទីចាប់ផ្តើមវិញដោយមានខ្សែជាប់ជើងនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកយើងមិនអាចរស់នៅលើពិភពលោកនេះតែម្នាក់ឯងនោះទេ ហើយយើងត្រូវតែធ្វើការជាមួយគ្នាដើម្បីធ្វើឲ្យជីវិតរស់នៅរបស់យើងប្រសើរឡើងជាមួយគ្នា។

## ៤. ការណែនាំមេរៀន

តើអ្នកណាចូលចិត្តលេងទឹកភ្លៀងខ្លះ? តើអ្នកធ្លាប់មានបទពិសោធន៍ជាមួយទឹកជំនន់ជ្រៅជាងគេនៅរដូវវស្សាដែរឬទេ? តើអ្នកធ្លាប់គិតថាកម្ពស់ទឹកជំនន់អាចខ្ពស់ជាងភ្នំដែរឬទេ? ថ្ងៃនេះយើងនឹងស្វែងយល់ពីគ្រួសារមួយដែលទុកចិត្តព្រះឲ្យទ្រង់ថែរក្សាពួកគេក្នុងពេលមានទឹកជំនន់ដ៏ធំ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សប្ដាហ៍មុនយើងបានរៀនពី មនុស្សដែលនៅតែប្រព្រឹត្តអំពើបាបនិងឈប់ស្ដាប់បង្គាប់ព្រះដែលធ្វើឲ្យព្រះមិនសព្វព្រះទ័យ។ ព្រះបានប្រាប់ណូអេឲ្យសាងសង់ទូកធំមួយ ពីព្រោះព្រះអង្គចង់បំបាត់មនុស្សមានបាបទាំងអស់។ ណូអេដឹងថាគាត់អាចទុកចិត្តព្រះបានជានិច្ច ដូច្នេះគាត់បានធ្វើតាមបង្គាប់របស់ព្រះ ដោយបានសង់ទូកធំមួយដែលអាចផ្ទុកនូវសមាជិកគ្រួសារគាត់ និង សត្វទាំងអស់ផងដែរ។ ណូអេ និងគ្រួសាររបស់គាត់ រួមជាមួយនឹងសត្វ ទាំងអស់បានដើរចូលទៅក្នុងទូកហើយទ្វារក៏បានបិទ។ ទោះជាមនុស្សបានឃើញសត្វទាំងអស់បានដើរចូលទៅក្នុងទូកក៏ដោយ ក៏ពួកគេនៅតែមិនបានប្រែចិត្តជឿលើព្រះដែរ។ ប៉ុន្តែណូអេនិងក្រុមគ្រួសារគាត់បានដឹងថាពួកគេនៅតែអាចទុកចិត្តព្រះ ដូច្នេះពួកគេបាន ស្ដាប់បង្គាប់ព្រះ។

ព្រះគម្ពីរបានប្រាប់ថា បន្ទាប់ពីណូអេនិងក្រុមគ្រួសារបានចូលទៅក្នុងទូកមេឃក៏ចាប់ផ្ដើមភ្លៀង។ ភ្លៀងធ្លាក់ខ្លាំងរយៈពេល៤០ថ្ងៃ៤០យប់ជាប់គ្នា។ ទឹកភ្លៀងក៏ចាប់ផ្ដើមជន់ឡើង ហើយទូកក៏ចាប់ផ្ដើមអណ្ដែតនៅលើផ្ទៃទឹក។ ណូអេ និងក្រុមគ្រួសារបានទុកចិត្តលើព្រះដើម្បីឲ្យទ្រង់ថែរក្សាពួកគេឲ្យមានសុវត្ថិភាព ។ នៅពេលដែលទឹកឡើងកាន់តែខ្ពស់ជាងមុន ហើយទូកក៏បានអណ្ដែតនៅលើទឹក។ ទឹកក៏កាន់តែចំរើនឡើងជាលើសលុបទាល់តែលិចអស់ទាំងភ្នំទាំងឡាយអស់រលីងទៅ។ នៅតែណូអេ និងគ្រួសាររបស់គាត់មានសុវត្ថិភាព។ ពួកគេមិនភ័យខ្លាចអ្វីឡើយ ពីព្រោះពួកគេដឹងថាពួកគេអាចពឹងផ្អែកលើព្រះបាន។

បន្ទាប់ពី៤០ថ្ងៃ៤០យប់កន្លងទៅភ្លៀងក៏ឈប់ធ្លាក់មក។ ណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់ក៏មានសុវត្ថិ-ភាពនៅក្នុងទូក។ ទូកបានអណ្ដែតនៅលើមហាសាគរដ៏ធំល្វឹងល្វើយ។ ទីប្រជុំជន ទីក្រុង ភ្នំ និង ចំការទាំងអស់បានគ្របដណ្ដប់ពេញដោយទឹក។ បន្ទាប់ពីច្រើនថ្ងៃកន្លងទៅ ព្រះបានបញ្ជូនខ្យល់បក់មកលើផែនដី និងធ្វើឲ្យទឹកស្រកវិញ។ ពេលដែលទឹកចាប់ផ្ដើមស្រក ទូកក៏បានគៀងនៅលើកំពូលភ្នំអារ៉ារ៉ាត់។

ណូអេបានលែងព្រាបមួយចេញមកក្រៅ។ ប៉ុន្តែសត្វព្រាបមិនអាចរកកន្លែងណាទំបានទេ ដូច្នេះហើយវាក៏បានត្រឡប់ទៅវិញ។ មួយសប្ដាហ៍ក្រោយមកណូអេបានព្យាយាមម្ដងទៀត។ ពេលនេះសត្វព្រាបបានត្រឡប់មកវិញហើយបានពាំស្លឹកអូលីវមកជាមួយ។ ដូច្នេះណូអេបានដឹងថាទឹកមិនបានលិចគ្របលើដើមឈើទៀតទេ។ ហើយឆាប់ៗនេះដីក៏នឹងស្ងួតវិញដែរ។

បន្ទាប់ពីមួយសប្ដាហ៍ក្រោយមក ណូអេបានលែងព្រាបទៅម្ដងទៀត ហើយលើកនេះព្រាបនោះមិនបានត្រឡប់មកវិញទេ ពីព្រោះដីបានស្ងួតហើយ និងមានដើមឈើជាច្រើន។ នៅពេលដែលមានសុវត្ថិភាព ហើយដីបានស្ងួតផងអស់ហើយ ព្រះបានមានបន្ទូលប្រាប់ណូអេឲ្យចេញពីទូក។ ព្រះបានសន្យាជាមួយណូអេថាទ្រង់នឹងមិនបំផ្លាញផែនដីនេះដោយទឹកជំនន់ទៀតទេ។ ដូចដែលបានរំលឹកពីការសន្យារបស់ទ្រង់ ព្រះបានដាក់ឥន្ទធនូនៅលើមេឃជាទីសំគាល់ នៅពេលដែលយើងឃើញឥន្ទធនូ វានឹងរំលឹកយើងថាយើងអាចទុកចិត្តលើព្រះបានដែលទ្រង់តែងតែរក្សាការសន្យារបស់ទ្រង់។

យើងអាចពឹងផ្អែកលើព្រះបាន។ យើងអាចទុកចិត្តព្រះបានជានិច្ចថាព្រះអង្គស្រឡាញ់ ហើយដឹកនាំ និង តែងតែគង់ជាមួយយើងគ្រប់ពេល។ ទ្រង់តែងរក្សាការសន្យារបស់ទ្រង់ជានិច្ច ។ ព្រះអង្គធ្វើនូវអ្វីដែលល្អបំផុតសម្រាប់

យើងគ្រប់ពេល។ គ្មានហេតុផលណាដែលយើងត្រូវសង្ស័យថាព្រះអង្គភ្លេច ឬ បោះបង់យើងនោះទេ។ ព្រះអង្គបំភ្លឺផ្លូវសំរាប់យើងគ្រប់ពេល ពីព្រោះព្រះតែងតែអាចឱ្យយើងទុកចិត្តទ្រង់បាន។

**៦. សំនួរពិភាក្សា**

១. តើមានភ្លៀងធ្លាក់រយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់បានចូលទៅក្នុងទូកហើយ? *រយៈពេល៤០ថ្ងៃ៤០យប់*

២. តើអ្នកណាសន្យាថានឹងក្សាឲ្យណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់មានសុវត្ថភាព? *ព្រះ*

៣. ហេតុអ្វីបានជាណូអេ និងក្រុមគ្រួសារគាត់មិនភ័យខ្លាចក្នុងពេលមានទឹកជំនន់?
*ពីព្រោះពួកគេ បានដឹងថាគេអាចនឹងពឹងផ្អែកលើព្រះបាន*

៤. តើមានអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកដែលអ្នកអាចនឹងពឹងផ្អែកលើព្រះឲ្យជួយអ្នកបាន? *សូមឲ្យកុមារឆ្លើយ*

**៧. ល្បែងកំសាន្ត «ជញ្ជូនចានប្រណាំងគ្នា»**



**សម្ភារៈដែលត្រូវការ៖** ចានក្រដាស

១. ចែកកុមារជាពីរក្រុមហើយឲ្យចានក្រដាសមួយទៅក្រុមនីមួយៗ

២. ឲ្យកុមារឈរជាជួរ ហើយកុមារទី១ ត្រូវដាក់ចានក្រដាសនៅចន្លោះជើង ហើយដើរទៅកាន់កុមារបន្ទាប់ដែលឈរ(ចម្ងាយ២ម៉ែត្រពីគ្នា)។ ពួកគេត្រូវបន្តបញ្ជូនចាននោះឲ្យទៅដល់កុមារចុងក្រោយដោយមិនប្រើដៃនោះទេ។

៣. ក្រុមណាដែលអាចបញ្ជូនចាននោះទៅដល់កុមារចុងក្រោយបានមុនគេក្រុមនោះជាអ្នកឈ្នះ

៤. បន្ទាប់មកក្រុមដែលឈ្នះទាំងពីរត្រូវប្រកួតគ្នាម្តងទៀត ដើម្បីស្វែងរកអ្នកឈ្នះចុងក្រោយ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាមិនងាយស្រួលនោះទេក្នុងការបញ្ជូនចានក្រដាសទៅកាន់សមាជិកក្រុមដោយមិនប្រើដៃនោះ។ វាគឺមិនងាយស្រួលទេសម្រាប់ណូអេក្នុងការប្រមូលសត្វទាំងអស់ និងអាហារសម្រាប់រយៈពេល៤០ថ្ងៃមកក្នុងទូកនោះ។ ប៉ុន្តែគាត់នៅតែស្តាប់បង្គាប់ព្រះពីព្រោះគាត់ទុកចិត្តលើព្រះ។

**៨. ខគម្ពីរចងចាំ ទំនុកដំកើង ៣៣:២០**

**៩. ហត្ថកម្ម «ណូអេពឹងផ្អែកលើព្រះ»**



**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កូល័រផាត់ពណ៌ កន្ត្រៃ និងការជ័រ

១ ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេផាត់ពណ៌ឥន្ទនូ ទូក និងសត្វទាំងអស់។

២ កាត់រូបរង្វង់ និងទូកចេញមក។ បត់រូបរង្វង់នោះជាពីរ ហើយយករូបទូកទៅបិតនៅខាងលើរង្វង់នោះ។

៣ អ្នកអាចបិតឲ្យរូបនោះឈរបាន ហើយធ្វើឲ្យវាមានចលនាបានដោយប្រើស្កុតបិតនៅខាងចុងរូបទូក។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ណូអេពឹងផ្អែកលើព្រះ



